ADB

www.compliance.adb.org

ធនាគារអភិវឌ្ឍន៍អាស៊ី

# យន្តការគណនេយ្យភាព

## សូមស្តាប់សហគមន៍ដែលទទួលរងផលប៉ះពាល់ពីគំរោងផ្តល់មូលនិធិដោយ ធនាគារអភិវឌ្ឍន៍អាស៊ី និងការលើកកំពស់ប្រសិទ្ធិភាពនៃការអភិវឌ្ឍន៍



### អំពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB)

ADB គឺជាស្ថាប័នអភិវឌ្ឍន៍ហិរញ្ញវត្ថុពហុភាគីមួយដែលមានសមាជិក ៦៣ប្រទេសជាម្ចាស់ ។ ចក្ខុវិស័យរបស់ ADB គឺលុបបំបាត់ភាពក្រីក្រ នៅតំបន់អាស៊ី និងប៉ាស៊ីហ្វិក ។ តាមការផ្តល់ឥណទាន ជំនួយបច្ចេកទេស ជំនួយឥតសំណង ភាគទុនវិនិយោគ និងការធានាដល់រដ្ឋាភិបាល និងសហគ្រាសឯកជន នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ដែលជាសមាជិករបស់ខ្លួន ADB បានជួយលើកកំពស់កំរិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋតាមរយៈសកម្មភាពអភិវឌ្ឍន៍ជាច្រើន ។

### តើអ្វីទៅជាយន្តការគណនេយ្យភាពរបស់ ADB ?

នៅខែឧសភា ឆ្នាំ ២00៣ ADB បានអនុម័តយន្តការគណនេយ្យភាពថ្មីមួយ ដើម្បីជំនួសឱ្យមុខងារអធិការកិច្ចចាស់ ។ យន្តការនេះ ត្រូវបានបង្កើតឡើងដើម្បីផ្តល់នូវលទ្ធភាពឱ្យកាន់តែប្រសើរដល់ប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់ខ្លាំងពីគំរោងដែលផ្តល់មូលនិធិដោយ ADB ក្នុងការបញ្ចេញមតិ និងស្វែងរកដំណោះស្រាយបញ្ហាសំរាប់ពួកគេ មិនតែប៉ុណ្ណោះ យន្តការនេះក៏ប្រាប់ឱ្យដឹងផងដែរពីការរំលោភបំពាននានាលើគោលនយោបាយ និងនិតិវិធីរបស់ ADB ។

ការបង្កើតយន្តការនេះឡើង គឺជាកិច្ចប្រឹងប្រែងថ្មីមួយទៀត ដើម្បីលើកកំពស់ប្រសិទ្ធិភាពលើការអភិវឌ្ឍន៍ គុណភាព គំរោង និងតម្លាភាពរបស់ ADB ក្នុងប្រតិបត្តិការរបស់ខ្លួន។

លក្ខណៈពិសេសជាគន្លឹះនៃយន្តការនេះ គឺមុខងារទាំងពីររបស់វាដែលមានទំនាក់ទំនងគ្នា ពោលគឺការពិគ្រោះយោបល់ និងការពិនិត្យឡើងវិញលើការអនុវត្តន៍តាម ។ ទីមួយ គឺការពិគ្រោះយោបល់ ក្នុងចំណោមភាគីពាក់ព័ន្ធ ដោយផ្តោតលើការដោះស្រាយបញ្ហា ។ ប្រសិនបើគេពុំអាចឈានទៅរកដំណោះស្រាយសមស្របណាមួយទេ ការដាក់ពាក្យបណ្តឹងសំរាប់ពិគ្រោះយោបល់ គឺមិនយកជាការបានទេ ឬក៏ដំណើរការពិគ្រោះយោបល់បានឈានចូលដល់ដំណាក់កាលមួយទៀត និងមានការពាក់ព័ន្ធនឹងបញ្ហានៃ ការអនុវត្តន៍តាម ពេលនោះគេអាចដាក់សំណើសុំឱ្យមានការពិនិត្យឡើងវិញលើការអនុវត្តន៍តាម។

### តើអ្វីទៅជាដំណាក់កាលពិគ្រោះយោបល់?

- ដំណាក់កាលពិគ្រោះយោបល់ សំដៅជួយដល់ប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់ខ្លាំងពីគំរោងដែលផ្តល់មូលនិធិដោយ ADB ដើម្បីស្វែងរកដំណោះស្រាយចំពោះបញ្ហារបស់ពួកគេ ។ ដំណាក់កាលពិគ្រោះយោបល់នេះ ដឹកនាំដោយអ្នកសំរបសំរួលគំរោងពិសេស (Special Project Facilitator/SPF) របស់ ADB ។
- ដំណាក់កាលពិគ្រោះយោបល់ ចាប់ផ្តើមពីការពិចារណាលើភាពស្របច្បាប់នៃពាក្យបណ្តឹង ។ ប្រសិនបើពាក្យបណ្តឹង មានភាពសមស្រប នោះការយកចិត្តទុកដាក់នឹងផ្តោតទៅលើការស្វែងរកកិច្ចព្រមព្រៀងក្នុងចំណោមភាគីដែលពាក់ព័ន្ធទាំងអស់ ដូចជា ភាគីប្តឹងតវ៉ា ភាគីអនុវត្តគំរោងរដ្ឋាភិបាលប្រទេសកំពុងអភិវឌ្ឍន៍ដែលជាសមាជិកដែល ឬជាផ្នែកឯកជនដែលគាំទ្រដល់គំរោង និង ADB ។ ទោះយ៉ាងណាក៏ដោយ អ្នកសំរបសំរួលគំរោងពិសេស (SPF) របស់ ADB នឹងមិនជ្រៀតជ្រែកបញ្ហាផ្ទៃក្នុងរដ្ឋាភិបាលនៃប្រទេសកំពុងអភិវឌ្ឍន៍ដែលជាសមាជិកឡើយ ។
- អ្នកសំរបសំរួលគំរោងពិសេស (SPF) ជួយផ្តល់យោបល់បន្ថែមក្នុងការដោះស្រាយបញ្ហាដែលកើតឡើង ប៉ុន្តែមិនចូលជំនួសតួនាទីនៃការគ្រប់គ្រងគំរោងដែលអនុវត្តដោយនាយកដ្ឋានប្រតិបត្តិរបស់ ADB ទេ ។ អ្នកសំរបសំរួលគំរោងពិសេស នឹងរាយការណ៍ដោយផ្ទាល់ទៅប្រធាន ADB និងផ្តល់អនុសាសន៍ ដើម្បីដោះស្រាយលើពាក្យបណ្តឹង។ អ្នកសំរបសំរួលគំរោងពិសេស នឹងត្រួតពិនិត្យតាមដានផងដែរលើការអនុវត្តកិច្ចព្រមព្រៀងដែលទទួលបានពីដំណើរការពិគ្រោះយោបល់ ។

**" ខ្ញុំមានជំនឿយ៉ាងមាំថា ផ្តើមចេញពីការគាំទ្រពីភាគីពាក់ព័ន្ធទាំងអស់ យន្តការគណនេយ្យភាពនេះនឹងបំពេញតំរូវការបានយ៉ាងល្អដល់ពួកគេ ព្រោះថា ADB បានដោះស្រាយរាល់ពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់នៅនឹងមូលដ្ឋាន និងបានបង្កើតដំណើរការតម្លាភាពមួយដែលនឹងបង្កើនគណនេយ្យភាពរបស់ ADB បន្ថែមទៀត" ។**

TADAO CHINO, ប្រធាន ADB

សន្ទរកថាស្តីពីយន្តការគណនេយ្យភាពរបស់ ADB ដែលបានចូលជាធរមាន

នៅខែ ធ្នូ ឆ្នាំ ២០០៣

---



### តើអ្វីទៅជាតំណាក់កាលពិនិត្យឡើងវិញលើការអនុវត្តន៍តាម?

- ការពិនិត្យឡើងវិញលើការអនុវត្តន៏តាម ត្រូវបានគេយកចិត្តទុកដាក់លើផលប៉ះពាល់ផ្ទាល់ និងផលប៉ះពាល់លើសំភារៈដែលប្រជាពលរដ្ឋទទួលរងគ្រោះពីគំរោង និងថាតើផលប៉ះពាល់នេះបណ្តាលមកពីការរំលោភបំពានរបស់ ADB លើគោលនយោបាយប្រតិបត្តិ និងនិតីវិធីរបស់ខ្លួន ក្នុងការរៀបចំបង្កើត ឬការអនុវតន៏គំរោងដែរឬទេ ។ ការពិនិត្យឡើងវិញលើការអនុវត្តន៏តាម ត្រូវបានប្រតិបត្តិដោយក្រុមពិនិត្យឡើងវិញទៅលើការអនុវត្តន៏តាម (Compliance Review Panel/CRP) ឯករាជ្យមួយ ។

- ការពិនិត្យឡើងវិញលើការអនុវត្តន៏តាម ចាប់ផ្តើមពីអនុសាសន៏ដែលធ្វើឡើងដោយក្រុមពិនិត្យឯករាជ្យ ដាក់ទៅឱ្យក្រុមប្រឹក្សានាយកស្តីពីភាពសមស្របនៃសំណើ ដើម្បីធ្វើការពិនិត្យឡើងវិញលើការអនុវត្តន៏តាម ។ ប្រសិនបើអនុសាសន៏នេះទទួលការយល់ព្រម ក្រុមពិនិត្យនេះនឹងចាប់ផ្តើមធ្វើការស៊ើបអង្កេតឯករាជ្យ និងផ្តល់អនុសាសន៏ទៅឱ្យក្រុមប្រឹក្សានាយកដើម្បីធានាដល់ការគោរពតាមលក្ខខ័ណ្ឌគំរោង រួមទាំងការផ្លាស់ប្តូរវិធីដោះស្រាយក្នុងវិសាលភាព ឬការអនុវត្តន៏គំរោង ។

- ក្រុមពិនិត្យនេះត្រូវបានជួយគាំទ្រដោយលេខាធិការដ្ឋានមួយ ដែលជាការិយាល័យរបស់ក្រុមពិនិត្យឡើងវិញលើការអនុវត្តន៏តាម ។ ក្រុមពិនិត្យនេះ នឹងត្រួតពិនិត្យតាមដានផងដែរនូវការអនុវត្តន៏រាល់សកម្មភាពដោះស្រាយដែលអនុម័តដោយក្រុមប្រឹក្សានាយក ។

### តើនរណាខ្លះអាចដាក់ពាក្យបណ្តឹង ឬសំណើបាន?

- ក្រុមណាមួយក៏បានដែលមានប្រជាពលរដ្ឋចាប់ពី ពីរនាក់ឡើងទៅក្នុងប្រទេសដែលគំរោងទទួលមូលនិធិពី ADB កំពុងដំណើរការ ឬក៏ក្នុងប្រទេសជាសមាជិកណាមួយនៅជិតខាង ។ ក្រុមនេះអាចជា អង្គការមួយ សមាគមមួយ សង្គមជាតិមួយ ឬក្រុមឯកត្តជនដទៃទៀត ។
- អ្នកតំណាងមូលដ្ឋានម្នាក់ ត្រូវបានជ្រើសតាំងដោយប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់ពីគំរោង ។

- អ្នកតំណាងម្នាក់ដែលមិនបានរស់នៅមូលដ្ឋាន ដែលគំរោងកំពុងដំណើរការ គឺឋិតក្នុងករណីពិសេស ដែលគេមិនអាចរកអ្នកតំណាងនៅមូលដ្ឋានបាន និងមានការយល់ព្រមពីអ្នកសំរបសំរួលគំរោងពិសេស (SPF) ។ ក្នុងករណីដាក់សំណើ ត្រូវមានការយល់ព្រមពីក្រុមពិនិត្យឡើងវិញលើការអនុវត្តន៏តាម (CRP) ។

- ក្នុងករណីពិសេស សមាជិកក្រុមប្រឹក្សានាយកណាម្នាក់ អាចដាក់សំណើសុំឱ្យមានការពិនិត្យឡើងវិញលើគំរោង ដែលកំពុងដំណើរការ ។



## តើត្រូវដាក់ពាក្យបណ្តឹង ឬសំណើយ៉ាងដូចម្តេច?

ដំបូង អ្នកប្តឹងត្រូវដាក់ពាក្យបណ្តឹងទៅអ្នកសំរបសំរួលគំរោងពិសេស (SPF) ។ ប្រសិនបើពាក្យបណ្តឹងនេះត្រូវបានគេយល់ថាមិនមានភាពសមស្រប ប្រសិនពួកគេមិនពេញចិត្តនឹងដំណើរការពិគ្រោះយោបល់ ឬប្រសិនបើដំណើរការពិគ្រោះយោបល់បានឈានទៅដល់ដំណាក់កាលមួយទៀត និងមានការពាក់ព័ន្ធនឹងបញ្ហាការអនុវត្តន៏តាម អ្នកប្តឹងអាចដាក់សំណើរទៅក្រុមពិនិត្យឡើងវិញលើការអនុវត្តន៏តាម (CRP) ។

ពាក្យបណ្តឹង ឬ សំណើរសុំ ត្រូវតែសរសេរជាលាយល័ក្ខណ៏អក្សរ ហើយផ្ញើរទៅអ្នកសំរបសំរួលគំរោងពិសេស (SPF) ឬលេខារបស់គាត់ ឬក៏ ក្រុមពិនិត្យឡើងវិញលើការអនុវត្តន៏តាម (CRP) តាមសំបុត្រ ឬតាមទូរសារ ឬ តាមអ៊ីម៉ែល ឬយកទៅផ្ញើរដោយផ្ទាល់នៅទីស្នាក់ការកណ្តាល ADB ឬផ្ញើតាមនិវាសដ្ឋានបេសកកម្ម ADB ឬការិយាល័យតំណាងណាមួយក៏បាន ។ ពាក្យបណ្តឹង/សំណើអាចសរសេរជាភាសាអង់គ្លេស ឬប្រសិនបើអ្នកប្តឹង/អ្នកដាក់សំណើមិនអាចបកប្រែពាក្យបណ្តឹង/សំណើឱ្យទៅជាភាសាអង់គ្លេសបានទេ គេអាចសរសេរជាភាសាជាតិ ឬភាសាផ្លូវការណាមួយនៃប្រទេសកំពុងអភិវឌ្ឍន៏ដែលជាសមាជិក របស់ ADB ក៏បានដែរ។ អត្តសញ្ញាណរបស់អ្នកប្តឹងនឹងត្រូវបានរក្សាការសំងាត់បើសិនជាមានសំណួមពរ ប៉ុន្តែ គេនឹងមិនទទួលយកពាក្យបណ្តឹងអនាមិកទេ ។

## តើបញ្ហាណាខ្លះដែលបណ្តឹង/សំណើមិនមានលក្ខណៈសមស្រប?

- សេចក្តីសំរេចធ្វើឡើងដោយ ADB ឬការសំរេចរបស់អ្នកអនុវត្តគំរោងទាក់ទិននឹងការដេញថ្លៃសំភារៈសេវាកម្មនិងសេវាកម្មពិគ្រោះយោបល់។ បញ្ហាទាំងនេះគួរត្រូវបានដោះស្រាយនៅការិយាល័យសេវាកម្មប្រតិបត្តិកណ្តាលរបស់ ADB ដែលអាចទាក់ទងបានតាមគេហទំព័រ www.adb.org/COSO ។
- ការចោទប្រកាន់ពីការកេងបន្លំ និងអំពើពុករលួយនៅក្នុងគំរោង ឬប្រព្រឹត្តដោយបុគ្គលិក ADB ។ បញ្ហាទាំងនេះគួរត្រូវបានដោះស្រាយនៅអង្គភាពប្រឆាំងអំពើពុករលួយរបស់ ADB នៃការិយាល័យអគ្គសវនករដែលគេអាចទាក់ទងបានតាមគេហទំព័រ www.adb.org/Anticorruption/unit.asp ។
- របាយការណ៏បញ្ចប់របស់គំរោង ជាធម្មតា ត្រូវបានបោះពុម្ពផ្សាយក្នុងរយៈពេលពីរឆ្នាំ បន្ទាប់ពីគំរោងបានចប់សព្វគ្រប់ ។
- បញ្ហាកើតឡើងទាំងឡាយ ត្រូវបានគិតគូររួចហើយក្នុងមុខងារអធិការកិច្ចចាស់ ឬត្រូវបានគិតគូរដោយក្រុមពិនិត្យឡើងវិញលើការអនុវត្តន៏តាម (CRP) ។
- គំរោងផ្នែកឯកជន ដែលទទួលបានការយល់ព្រមនៅមុន ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៣។




ពត៌មានបន្ថែម ស្តីពីយន្តការគណនេយ្យភាពរបស់ ADB សូមមើលគេហទំព័រ **www.compliance.adb.org** ។

## ខ្លឹមសារនៃពាក្យបណ្ដឹង

ពាក្យបណ្ដឹងត្រូវបញ្ជាក់ឱ្យបានច្បាស់នូវចំនុចដូចខាងក្រោមៈ

- អ្នកប្ដឹង គឺជាអ្នក ឬទំនងជាអ្នកដែលទទួលរងផលប៉ះពាល់ខ្លាំងដោយផ្ទាល់លើផ្នែកសំភារៈដោយសារគំរោងដែលបានមូលនិធិពី ADB ។
- ការទាមទារសំណងលើការខូចខាតផ្នែកសំភារៈ គឺជា ឬ នឹងជាលទ្ធផលនៃសកម្មភាព ឬការមិនបានគិតគូរទុកជាមុនក្នុងអំឡុង ពេលដែល ADB រៀបចំបង្កើត ឬអនុវត្តន៍គំរោងរបស់ខ្លួន ។
- ការពណ៌នាអំពីសិទ្ធិ និងអត្ថប្រយោជន៍ ដែលត្រូវបាន ឬនឹងទំនងជាត្រូវទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរពីគំរោងដែលផ្ដល់មូលនិធិដោយ ADB ។
- បង្ហាញពីអត្តសញ្ញាណអ្នកប្ដឹង (អ្នកតំណាងណាម្នាក់) និងអាស័យដ្ឋានទាក់ទង និងបើសិនមានសំណូមពរថា អត្តសញ្ញាណរបស់អ្នកប្ដឹងត្រូវរក្សាការសំងាត់ សូមបញ្ជាក់ពីហេតុផលផង ។
- បើសិនជាមានអ្នកតំណាង សូមបង្ហាញប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់ដោយគំរោង និងភស្តុតាងនៃការទទួលស្គាល់ ដើម្បីតំណាងឱ្យពួកគេ ។
- ការពិពណ៌នាដោយសង្ខេបពីគំរោងដែលទទួលមូលនិធិពី ADB រួមមានឈ្មោះ និងទីតាំងរបស់គំរោង បើសិនជាមាន។
- លទ្ធផល ឬដំណោះស្រាយដែលចង់បានរបស់ប្រជាពលរដ្ឋទទួលរងគ្រោះដោយសារគំរោង បើយល់ឃើញថា ADB គួរផ្ដល់ ឬគួរជួយតាមរយៈអ្នកសំរបសំរួលគំរោងពិសេស (SPF) ។
- ការពិពណ៌នាអំពីចេតនាល្អរបស់អ្នកប្ដឹង ក្នុងការដោះស្រាយបញ្ហា ជាមុនជាមួយនាយកដ្ឋានប្រតិបត្តិការដែលពាក់ព័ន្ធ ។
- ការពន្យល់ហេតុផលថា ហេតុអ្វីបានជាពតិមានណាមួយខាងលើ មិនអាចផ្ដល់ឱ្យបាន។
- រាល់បញ្ហា ឬពតិមានដែលពាក់ពន្ធ័ត្រូវមានឯកសារគាំទ្រភ្ជាប់មកជាមួយ ។

អ្នកសំរបសំរួលគំរោងពិសេស (SPF) អាចទាក់ទងបានតាមៈ

**Special Project Facilitator**
Asian Development Bank
6 ADB Avenue
Mandaluyong City 1550
Philippines

ទូរស័ព្ទ: + 632 632-4825

ទូរសារ: + 632 636-2490

អ៊ីម៉ែល: spf@adb.org

អ៊ិនធើណែត: www.adb.org/spf

## ខ្លឹមសារនៃការដាក់សំណើដើម្បីសុំការពិនិត្យឡើងវិញលើការអនុវត្តន៍តាម

សំណើត្រូវបញ្ជាក់ឱ្យបានច្បាស់នៅចំនុចដូចខាងក្រោមៈ

- អ្នកដាក់សំណើ គឺជាអ្នក ឬទំនងជាអ្នកដែលទទួលរងគ្រោះធ្ងន់ធ្ងរផ្ទាល់លើផ្នែកសំភារៈដោយគំរោងដែលផ្ដល់មូលនិធិដោយ ADB ។
- ការទាមទារសំណងលើការខូចខាតលើផ្នែកសំភារៈ គឺជា ឬនឹងជាលទ្ធផលនៃសកម្មភាព ឬការមិនបានគិតគូរទុកជាមុននូវការមិនបានអនុវត្តតាមគោលនយោបាយប្រតិបត្តិនិងនិតិវិធីក្នុងអំឡុង ពេលដែល ADB រៀបចំបង្កើត ឬអនុវត្តគំរោងរបស់ខ្លួន ។
- ការពិពណ៌នាពីសិទ្ធិ និងអត្ថប្រយោជន៍ដែលត្រូវបាន ឬទំនងជាត្រូវបានទទួលផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរលើផ្នែកសំភារៈ ដោយគំរោងដែលបានទទួលមូលនិធិពី ADB ។
- បង្ហាញពីអត្តសញ្ញាណអ្នកដាក់សំណើ និងអាស័យដ្ឋានសំរាប់ធ្វើការ ទាក់ទងព្រមជាមួយនឹងហេតុផល ប្រសិនបើមានសំណូមពរឱ្យរក្សាការសំងាត់ ។
- បើសិនជាមានអ្នកតំណាង សូមបង្ហាញប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់ដោយគំរោង និងភស្តុតាងនៃការទទួលស្គាល់ដើម្បីតំណាងឱ្យពួកគេ ។
- ការពិពណ៌នាដោយសង្ខេបពីគំរោងដែលទទួលមូលនិធិពី ADB រួមមានឈ្មោះ និងទីតាំងរបស់គំរោង ។
- លទ្ធផល ឬដំណោះស្រាយដែលចង់បានរបស់ប្រជាពលរដ្ឋទទួលរងគ្រោះដោយសារគំរោង បើយល់ឃើញថា ADB គួរផ្ដល់ ។
- ការពន្យល់ពីលទ្ធផលនៃកិច្ចខំប្រឹងប្រែងរបស់អ្នកដាក់សំណើ ដើម្បីដោះស្រាយបណ្ដឹងជាមុន ជាមួយអ្នកសំរបសំរួល គំរោងពិសេស (SPF) (ឬប្រសិនបើ អ្នកសំរបសំរួលគំរោងពិសេស (SPF) បានបដិសេធនូវពាក្យបណ្ដឹងថា មិនមានភាពសមស្រប នោះត្រូវធ្វើការពន្យល់ឱ្យបានច្បាស់ថាតើហេតុអ្វីបានជាសំណើនេះមានភាពសមស្របសំរាប់ធ្វើការពិនិត្យឡើងវិញ លើការអនុវត្តន៍តាម) ។
- ការពន្យល់ពីហេតុផលថា ហេតុអ្វីបានជាពតិមានណាមួយខាងលើ មិនអាចផ្ដល់បាន។
- រាល់បញ្ហា ឬពតិមានពាក់ព័ន្ធត្រូវមានឯកសារគាំទ្រភ្ជាប់មកជាមួយ ។

ក្រុមពិនិត្យឡើងវិញលើការអនុវត្តន៍តាម (CRP) អាចទាក់ទងបានតាមៈ

**Secretary, Compliance Review Panel**
Asian Development Bank
6 ADB Avenue
Mandaluyong City 1550
Philippines

ទូរស័ព្ទ: + 632 632-4149

ទូរសារ: + 632 636-2088

អ៊ីម៉ែល: crp@adb.org

អ៊ិនធើណែត: www.compliance.adb.org

អត្ថបទជាភាសាអង់គ្លេសបានបោះពុម្ពផ្សាយនៅខែមិនា ២០០៤ ។

អត្ថបទនេះត្រូវបានបកប្រែចេញពីអត្ថបទជាភាសាអង់គ្លេស ក្នុងករណីមានភាពលំអៀង ឬភាពផ្ទុយគ្នាពីអត្ថបទដើម អត្ថបទជាភាសាអង់គ្លេស គឺជាឯកសារយោងផ្លូវការតែមួយគត់ ។ អត្ថបទជាភាសាខ្មែរនេះ បានបោះពុម្ពផ្សាយនៅខែតុលា ២០០៤ ។